# ទស្សនវិទូ ក្រាតែស

## Cratès

ក្រាតែស ដែលជាកូនប្រុសរបស់លោក Ascondo ជាអ្នកទីក្រុង Thèbes។ លោកគឺជាសាវ័កនៃក្រុមទស្សនវិទូទុទិដ្ឋនិយមដែលមាននាមដ៏ល្បីម្នាក់។ឪយ៉ូហ្សែនបានអះអាងថាខ្លួនបាននែនាំអោយលោកទុកដីរបស់លោកអោយសត្វចៀមហើយអោយបោះប្រាក់ទាំងប៉ុន្មានដែលលោកមានទៅក្នុងសមុទ្រ។លោកធ្លាប់បានយកដំបងវាយឪពុកម្តាយខ្លួនឯង ជាញយៗ ពេលដែលពួកគេមកជួបលោកដើម្បីព្យាយាមបង្វែរលោកចេញពីជីវិតថ្មីរបស់លោកប៉ុន្តែលោកនៅតែមិនអាចមាននរណាបង្វែរបង្វិលលោកបានឡើយ។Démétrion បានរៀបរាប់ប្រាប់ថាក្រាតែសបានដាក់លុយនៅធនាគារក្នុងលក្ខខណ្ឌដូចនេះ៖ថាបើកូនប្រុសទាំងអស់របស់លោករស់នៅដូចមនុស្សគ្រប់គ្នា នោះលោកនឹងប្រគល់លុយទាំងនោះជូនទៅពួកគេទាំងអស់។ផ្ទុយទៅ វិញ បើពួកគេរាប់អានទស្សនវិជ្ជា នោះលោកនឹងប្រគល់លុយទាំងនោះទៅប្រជាជនក្នុងស្រុក ដោយហេតុថា បើពួកគេរាប់អានទស្សនវិជ្ជា នោះពួកគេគ្មានត្រូវការអ្វីឡើយ។